THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**William R. Hite, Jr., Ed.D.**
នាយក

ថ្ងៃទី 8 ខែមីនា ឆ្នាំ 2021

មាតាបិតា និងគ្រួសារមណ្ឌលសាលា Philadelphia ជាទីមេត្រី!

ខ្ញុំមានសេចក្ដីរីករាយសូមជម្រាបថា ពេលនេះ សហព័ន្ធគ្រូបង្រៀន Philadelphia (Philadelphia Federation of Teachers(PFT)) បានពិនិត្យឡើងវិញរួចហើយនូវភាពត្រៀមជាស្រេច សម្រាប់សាលារៀនចំនួន 45 បន្ថែម ដែលសាលារៀនទាំងអស់នេះនឹងបើកទ្វារឡើងវិញសម្រាប់ការសិក្សាដោយផ្ទាល់ ចាប់ពីថ្ងៃចន្ទ ទី 15 ខែមីនាតទៅ សម្រាប់សិស្សថ្នាក់ PreK-2 ដែលគ្រួសារបានជ្រើសយកការសិក្សាតាមប្រព័ន្ធកូនកាត់ កាលពីរដូវឈើជ្រុះស្លឹក។ គ្រូបង្រៀនថ្នាក់ PreK-2 និងបុគ្គលិកជំនួយនៅសាលារៀនទាំង 45 នេះ នឹងត្រឡប់មកអគារសាលារៀនវិញនៅថ្ងៃពុធ ទី10 ខែមីនា ដើម្បីរៀបចំត្រៀមសម្រាប់ការត្រឡប់របស់សិស្សក្មេងៗរបស់យើង។ សាលារៀនទាំងនេះអនុវត្តតាមក្រុមសាលារៀនទីមួយចំនួន 53 ដែលបានបើកទ្វារឡើងវីសម្រាប់ការសិក្សាដោយផ្ទាល់ នៅថ្ងៃនេះ។

សាលារៀនចំនួន 45 ដែលបើកទ្វារសម្រាប់ការសិក្សាដោយផ្ទាល់ នៅថ្ងៃទី15 ខែមីនា មានឈ្មោះដូចខាងក្រោម៖

| | | |
|---|---|---|
| Alexander Adaire School | A.L. Fitzpatrick School | General George A. McCall School |
| Rudolph Blankenburg School | Benjamin Franklin School | Delaplaine McDaniel School |
| Joseph H. Brown School | Horatio B. Hackett School | Morton McMichael School |
| Lewis C. Cassidy School | Haverford Center | General George G. Meade School |
| Benjamin B. Comegys School | Charles W. Henry School | John M. Patterson School |
| Jay Cooke Elementary School | Thomas Holme School | Thomas M. Peirce School |
| William Cramp School | Francis Hopkinson School | Samuel Pennypacker School |
| Kennedy C. Crossan School | William H. Hunter School | Robert B. Pollock School |
| William Dick School | Andrew Jackson School | Potter-Thomas School |
| Hamilton Disston School | Abram Jenks School | Rhawnhurst School |
| Tanner Duckrey School | General Philip Kearney School | Philip H. Sheridan School |
| Ellwood School | William D. Kelley School | Edwin M. Stanton School |
| Eleanor C. Emlen School | John B. Kelly School | Vare-Washington Elementary School |
| Louis H. Farrell School | Robert E. Lamberton | John Welsh School |

| | | |
|---|---|---|
| | Elementary School | |
| D. Newlin Fell School | James Logan School | Widener Memorial School |

ជាផ្នែកនៃកិច្ចព្រមព្រៀងរួមដំបូង កង្ហារបង្អួច ដែលបានបំពាក់ពីមុននៅក្នុងថ្នាក់រៀននៅសាលារៀនទាំងនេះ នឹងត្រូវប្តូរវិញ ជំនួយដោយម៉ាស៊ីនបន្សុទ្ធខ្យល់ មុនពេលសិស្សវិលត្រឡប់មកសាលារៀន។

PFT នឹងបន្តធ្វើការពិនិត្យឡើងវិញលើភាពត្រៀមជាស្រេចរបស់សាលារៀន ដោយមានគោលដៅប្រកាសពីកាលបរិច្ឆេទវិលត្រឡប់ សម្រាប់សាលារៀននៅសល់ ដែលផ្តល់កម្មវិធីសិក្សាដល់សិស្សថ្នាក់ PreK-2 នៅមុនថ្ងៃទី 22 ខែមីនា ឆ្នាំ 2021។ ពេលណាការពិនិត្យឡើងវិញលើភាពត្រៀមជាស្រេចសម្រាប់សាលារៀន PreK-2 ទាំងអស់បានធ្វើរួចរាល់  PFT នឹងចាប់ផ្តើមធ្វើការពិនិត្យឡើងវិញសម្រាប់សាលារៀននៅសល់ ដែលផ្តល់កម្មវិធីសិក្សាដល់សិស្សថ្នាក់ទីបី ដល់ទី 12 ដើម្បីឲ្យក្រុមសិស្សផ្សេងទៀតនេះអាចចាប់ផ្តើមសិក្សាដោយផ្ទាល់ជាបណ្តើរៗ និងប្រកបដោយសុវត្ថិភាព។

ដូចបានជូនដំណឹងកន្លងមករួចហើយ គ្រួសារសិស្សថ្នាក់ PreK-2 ដែលតាំងពីដំបូងបានជ្រើសយកការសិក្សាតាមប្រព័ន្ធឌីជីថល 100% នឹងអាចជ្រើសរើសចូលរួមការសិក្សាតាមប្រព័ន្ធកូនកាត់បាន បន្ទាប់ពីសិស្សថ្នាក់ PreK-2 ទាំងអស់ ដែលសិក្សាតាមប្រព័ន្ធកូនកាត់ បានចាប់ផ្តើមដោយជោគជ័យ។

ជារឿងកក់ក្តៅក្នុងចិត្ត ដែលយើងជួបសិស្សរបស់យើងជាថ្មីនៅសាលារៀនរបស់យើងនៅថ្ងៃនេះ ក្រោយពីរយៈពេលជិតមួយឆ្នាំ ហើយខ្ញុំទន្ទឹមទទួលស្វាគមន៍សិស្សក្មេងៗរបស់យើងបន្ថែមទៀតដោយសុវត្ថិភាពសម្រាប់ការសិក្សាដោយផ្ទាល់នៅសប្តាហ៍ក្រោយ និងប៉ុន្មានសប្តាហ៍ទៀត។ សូមអរគុណចំពោះអ្នកដែលបន្តអត់ធ្មត់ ខណៈដែលយើងបន្តអនុវត្តកការងារដ៏សំខាន់ក្នុងការបើកអគារសាលារៀនរបស់យើងឡើងវិញ។ សូមចូលទៅ  philasd.org/aes ដើម្បីស្វែងយល់បន្ថែមអំពីវិធានការសុវត្ថិភាពជាច្រើនស្រទាប់ ដែលយើងមាន និងអំពីរបៀបដែលយើងគ្រប់គ្នាអាចចូលរួមបាន ដើម្បីការពារខ្លួនយើង និងងអ្នកផ្សេងទៀតក្នុងអំឡុងពេលនៅសាលារៀន។

ដោយសេចក្តីរ៉ាប់អាន!



William R. Hite Jr., Ed.D.
នាយក
មណ្ឌលសាលា Philadelphia